អង្គការសហការ
INTERNATIONAL COOPERATION CAMBODIA

អង្គការ អាយស៊ីស៊ី

# របាយការណ៍ប្រចាំឆ្នាំ២០១៦



ពង្រឹងសហគមន៍ ជាតិរឹងមាំ

# សេចក្តីផ្តើម

ឆ្នាំ២០១៦ ជាឆ្នាំអង្គការអាយស៊ីស៊ី-គម្រោងផាស (កាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងស្មារតីសហគមន៍ជនបទ) ត្រូវបានបញ្ចប់ បន្ទាប់ពីការអនុវត្តន៍ទទួលបានជោគជ័យក្នុងដំណាក់កាលទី១ និង ទី២។ ក្នុងដំណាក់កាលចាកចេញ គឺធ្វើយ៉ាងណាឲ្យប្រាកដថា សហគមន៍កសិកម្មចំនួនបួន ក្នុងស្រុកព្រះស្តេច ខេត្តព្រៃវែង មានស្ថានភាពរឹងមាំ និងឯករាជ្យគ្រប់គ្រាន់ ដើម្បីអាចបន្តដោយខ្លួនឯងទោះបីជាលក្ខណៈបុគ្គល និងជាក្រុមក្តី តួយ៉ាងដូចជា ក្រុមជួយខ្លួនឯងដែលបានបង្កើតឡើងក្រោមការសម្របសម្រួលរបស់គម្រោងផាស។ ក្នុងចេតនាគឺនៅតែពង្រឹងសហគមន៍កសិកម្មទាំងនេះ នូវអាជីវកម្មផ្នែកសង្គម ដែលកំពុងសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន។ មានហេតុផលមួយដែលគួរជាទីមោទនៈភាពពីលទ្ធផល និង ផលប៉ះពាល់នៃការងាររបស់គម្រោងផាស ក្នុងស្រុកព្រះស្តេចក្នុងឆ្នាំកន្លងមក នោះគឺ ការផ្តល់អំណាចដល់កសិករក្នុងស្រុកជាចម្បង។អង្គការអាយស៊ីស៊ី នៅតែបន្តធ្វើការជាមួយកសិករ និងបណ្តាញរបស់ពួកគេ តាមរយៈ គម្រោងទប់ស្កាត់ការជួញដូរមនុស្ស (Trafficking Response) ជាគម្រោងថ្មីដោយផ្តោតលើ ការកាត់បន្ថយ ការជួញដូរកម្លាំងពលកម្ម និង ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និង ទាសភាពសម័យទំនើប ក្នុងស្រុកព្រះស្តេច(សូមមើលបន្ថែម ដូចខាងក្រោម)។




ក្នុងឆ្នាំ២០១៦ អង្គការអាយស៊ីស៊ី បានចាប់ផ្តើមនូវដំណាក់កាលថ្មីសម្រាប់គម្រោងពីរដែលមានស្រាប់ គឺអ៊ីអូធីស៊ី៣ និង អាយប៊ីស៊ីឌីអ៊ី២។ លើសពីនេះទៀត កម្មវិធីអភិវឌ្ឍន៍អង្គការ (Organisational Development programs) ត្រូវបានអនុវត្តមានផ្នែកអភិក្រមយកសិទ្ធិជាមូលដ្ឋាន ប្រឹក្សាយោបល់ ការចូលរួមរបស់កុមារ និងការសិក្សាស្រាវជ្រាវ និងប្រមើមើលពីនិន្នាការ។ ការផ្តួចផ្តើមទាំងនេះ បានពង្រឹង អាយស៊ីស៊ី ក្នុងនាមជាអង្គការមួយ។

ជាងនេះទៅទៀត អង្គការអាយស៊ីស៊ី ត្រូវបានពង្រឹងតាមរយៈការផ្តោតលើការគ្រប់គ្រងគុណភាព និង ការអនុវត្តន៍ស្តង់ដារគុណភាពអប្បបរមាថ្មីរបស់អាយស៊ីស៊ី នៅគ្រប់កម្រិតទាំងអស់ក្នុងអង្គការទាំងមូល អង្គការថែមទាំងផ្តោតលើវិធីសាស្ត្រតស៊ូមតិរបស់អាយស៊ីស៊ី និង របៀបធ្វើការតស៊ូមតិបែបយុទ្ធសាស្ត្រក្នុងគម្រោងនានារបស់អង្គការអាយស៊ីស៊ី។

អាយស៊ីស៊ី ប៊ីយ៉ន (ICC Beyond) បានចាប់ផ្តើម ក្នុងឆ្នាំ២០១៦ វាជាកម្មវិធីប្រឹក្សាយោបល់ សម្រាប់បណ្តាអង្គការសង្គមស៊ីវិលដោយផ្តល់សេវាកម្មផ្សេងៗ ទាក់ទងនឹងការរៀបចំ ផ្នែករដ្ឋបាល និងការងារអភិវឌ្ឍន៍។

# ធ្វើការជាមួយអ្នកត្រូវបានគេយកចិត្តទុកដាក់តិចតួច

គម្រោងប្រឆាំងការជួញដូរមនុស្ស ដែលទើបតែចាប់ផ្តើមថ្មីៗនេះហៅថា ការទប់ស្កាត់ការជួញដូរមនុស្ស ក្នុងឆ្នាំ២០១៦ បានធ្វើការសិក្សាស្រាវជ្រាវ និង សាកល្បងពីរបៀបដើម្បីកាត់បន្ថយការជួញដូរមនុស្សក្នុងស្រុកព្រះស្តេច។អង្គការអាយស៊ីស៊ីបាន និង កំពុងប្រតិបត្តិការក្នុងស្រុកនេះជាច្រើនឆ្នាំមកហើយហើយ ជាសាក្សីដែលឃើញមានការកើនឡើងនូវកម្រិតនៃចំណាកស្រុកកំលាំងពលកម្ម ទាំងស្របច្បាប់ និងខុសច្បាប់។ គោលដៅចម្បង ក្នុងការធ្វើចំណាកស្រុកទៅក្រៅប្រទេសនោះគឺប្រទេសថៃ ហើយការធ្វើចំណាកស្រុកកម្លាំងពលកម្មភាគច្រើន ទៅប្រទេសថៃ គឺខុសច្បាប់។ ចំណាកស្រុកមួយចំនួនប្រឈមនឹងបញ្ហាជាមួយអាជ្ញាធរថៃ ឧទាហរណ៍អ្នកខ្លះត្រូវបានចាប់ខ្លួន ឬក៏បញ្ជូនទៅពន្ធនាគារ។ ទោះបី ចំនួនអ្នកចំណាកស្រុកពីស្រុកព្រះស្តេចទៅប្រទេសថៃ មានកម្រិតខ្ពស់ អ្នកភូមិជាច្រើន នៅតែមិនបានយល់ពីការរំលោភបំពានកម្លាំងពលកម្ម និងការជួញដូរមនុស្ស ពាក់ព័ន្ធនឹងចំណាកស្រុកកម្លាំងពលកម្ម ការបង្កើនការយល់ដឹង គឺជាផ្នែកមួយនៃគោលបំណងរបស់គម្រោង ទប់ស្កាត់ការជួញដូរមនុស្ស គ្រោងនឹងដោះស្រាយ។

អង្គការអាយស៊ីស៊ី បានសិក្សាឃើញថាចំណាកស្រុកកម្លាំងពលកម្ម ធ្វើឲ្យប៉ះពាល់ដល់ស្ថាប័នព្រះពុទ្ធសាសនាផងដែរ។ វត្តអារាមភាគច្រើន ដែលស្ថិតក្នុងតំបន់គោលដៅរបស់អង្គការក្នុងស្រុកព្រះស្តេច មានព្រះសង្ឃដែលមានអាយុក្រោម១៨ឆ្នាំ ហើយព្រះសង្ឃអង្គខ្លះមានអាយុរហូតដល់១០ឆ្នាំទៀតផង។

នេះជានិន្នាការថ្មីមួយ ដែលវត្តអារាមកំពុងទទួលយកក្មេងប្រុសច្រើនបំបួសជាព្រះសង្ឃ។ វាជាការពិតដែលក្មេងប្រុសៗភាគច្រើន ត្រូវបានទទួលយកឲ្យស្នាក់នៅក្នុងវត្ត ដើម្បីឲ្យវត្តនៅតែដំណើរការបាន។ មួយវិញទៀត ភាពក្រីក្រជំរុញឲ្យឪពុកម្តាយបញ្ចូលក្មេងប្រុសដែលជាកូនទៅរស់នៅក្នុងវត្ត ដើម្បីឲ្យព្រះសង្ឃជំទៃទៀតជួយមើលការខុសត្រូវ ឥឡូវហាក់ដូចជាកាន់តែច្រើនជាងឆ្នាំមុនៗ។ អង្គការអាយស៊ីស៊ី បានរកឃើញថាពេលព្រះសង្ឃក្មេងៗចាកចេញពីវត្ត គឺតម្រូវឲ្យគាត់ស្វែងរកការងារដើម្បីផ្គត់ផ្គង់គ្រួសារ។ ភាគច្រើននៃព្រះសង្ឃក្មេងៗ ធ្វើចំណាកទៅធ្វើការងារសំណង់ ការងាររោងចក្រ ឬស្វែងរកការងារនៅក្រៅប្រទេស ដូចជាប្រទេសថៃជាដើម។ លើសពីនេះទៀត ព្រះសង្ឃក្មេងៗមានប្រវត្តិអប់រំទាប និងមកពីគ្រួសារខ្សត់ខ្សោយខ្លាំង ហេតុនេះការធ្វើចំណាកស្រុកស្វែងរកការងារ គឺជាជម្រើសតែមួយគត់ បន្ទាប់ពីចាកចេញពីវត្ត។

ក្នុងឆ្នាំ២០១៦ គម្រោងទប់ស្កាត់ការជួញដូរមនុស្សបានបង្រៀនអ្នកដឹកនាំ ទាំងក្រុមជំនុំគ្រិស្តបរិស័ទ និង ស្ថាប័នព្រះពុទ្ធសាសនា អំពីហានិភ័យនៃការធ្វើចំណាកស្រុកខុសច្បាប់ និងការជួញដូរកម្លាំងពលកម្ម ក្នុងគោលបំណងដើម្បីផ្តល់អំណាចដល់ពួកគាត់ជួយការពារសហគមន៍ខ្លួនឯង។ ក្នុងនោះផងដែរ គម្រោងក៏បានជួយឲ្យអ្នកដឹកនាំសាសនា ស្វែងរកព័ត៌មានដែលអាចឲ្យពួកគាត់ អាចបង្ហាត់បង្ហាញអ្នកភូមិពីការធ្វើចំណាកស្រុកដោយស្របច្បាប់ និងសុវត្ថិភាព។



## ពង្រឹងក្រុមគោលដៅ

ថ្លៃសាលារបស់យុវជនជាច្រើន ត្រូវឪពុកម្តាយរបស់ពួកគេផ្ទាល់បង់ឲ្យ រហូតដល់សាកលវិទ្យាល័យ ក៏ប៉ុន្តែ យុវជនដែលមានឪពុកម្តាយក្រីក្រ ដោយពុំមានប្រាក់ចំណូលគ្រប់គ្រាន់សម្រាប់ការសិក្សារបស់កូនៗ ជារឿយៗ ពួកគាត់បង្ខំឲ្យកូនឈប់រៀន និង បោះបង់សេចក្តីស្រមៃរបស់ពួកគេ។

គម្រោងអាយស៊ីស៊ីហ្វាស(ការអភិវឌ្ឍន៍គ្រួសារនិងសាលារៀន) បានចូលមកដោះស្រាយបញ្ហានេះចាប់តាំងពីឆ្នាំ២០១៦ ដោយធ្វើការផ្ទាល់ជាមួយក្រុមយុវជន និង បង្កើតក្លឹបយុវជន នៅក្នុងខេត្តស្វាយរៀង។ យុវជនដែលជាសមាជិកក្លិបយុវជនទាំងនេះ រៀនពីរបៀបដែលហៅថា ប្រជាធិប្បតេយ្យក្នុងការរៀបចំក្រុម និងទទួលខុសត្រូវលើជោគវាសនារបស់ពួកគេផ្ទាល់។ តាមរយៈកីឡា ការជជែកពិភាក្សា និងការជួបជុំ ពួកគេកំពុងអភិវឌ្ឍរបៀបរស់នៅល្អ អាស្រ័យលើគុណតម្លៃស្នូលនៃជីវិត និងការជឿជាក់លើខ្លួនឯង។ ក្រុមការងារហ្វាស ក៏បានបង្រៀនយុវជនអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សិទ្ធិមនុស្ស ការគ្រប់គ្រងខ្លួនឯង ការធ្វើផែនការ ។ល។

ក្លឹបយុវជនភាគច្រើន សម្រេចចិត្តបង្កើតកម្មវិធីប្រាក់សន្សំ/ឥណទានផ្ទាល់របស់ពួកគេ ហើយគម្រោងហ្វាស គ្រាន់តែជួយសម្រួលក្នុងការរៀបចំកម្មវិធី និង បង្វឹកស្តីពីគោលបំណងដែលមានប្រយោជន៍ក្នុងការដាក់ប្រាក់កម្ចី។ ចំពោះយុវជនដែលមានសមត្ថភាពបន្តការសិក្សានៅវិទ្យាល័យ និង សាកលវិទ្យាល័យ ចាប់ផ្តើមសន្សំក្នុងក្លឹបយុវជន ដូច្នេះ ពួកគេមានថវិកាបន្ថែមសម្រាប់បង់ថ្លៃសាលា និង សម្ភារសិក្សា។ ជាមួយការអប់រំល្អ យុវជនមានឱកាសច្រើនក្នុងការស្វែងរកការងារ ដែលខ្លួនពេញចិត្ត។ ចំពោះយុវជនដែលមិនចង់ ឬមិនមានសមត្ថភាពសិក្សានៅវិទ្យាល័យ និង សាកលវិទ្យាល័យ ពួកគេបានធ្វើជំនួសមកវិញដោយការសន្សំប្រាក់/ឥណទាន ដើម្បីត្រៀមរៀបចំសម្រាប់អនាគតរបស់ពួកគេផ្ទាល់ ជាឧទាហរណ៍យុវជនដែលជាកសិករបានកំពុងយកប្រាក់កម្ចីដើម្បីចាប់ផ្តើមធ្វើស្រែត្រី ហើយអ្នកផ្សេងទៀតយកប្រាក់កម្ចីដើម្បីចាប់ផ្តើមអាជីវកម្មខ្នាតតូច។

លើសពីនេះទៀត ក្នុងឆ្នាំ២០១៦ ក្លឹបយុវជនមួយចំនួន បានប្រឡូកខ្លួនក្នុងកិច្ចការអភិវឌ្ឍន៍សហគមន៍ ដែលទទួលការកោតសរសើរពីប្រធានភូមិ និងអាជ្ញាធរមូលដ្ឋាន។ អង្គការអាយស៊ីស៊ី ជឿថាការចាត់បញ្ចូល និង ផ្តល់អំណាចដល់យុវជន គឺជាការបង្កើតមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ការឈានដល់ការផ្លាស់ប្តូរយូរអង្វែង និង ការរីកចម្រើនសម្រាប់ប្រជាជនកម្ពុជា ទាំងពេលបច្ចុប្បន្ន និង នាពេលអនាគត។

## ចងភ្ជាប់រវាងអាជ្ញាធរ និង សង្គមស៊ីវិល

គម្រោងវីអ៊ូធីស៊ី របស់អង្គការអោយស៊ីស៊ី (សម្លេងកុមារ) ធ្វើការឆ្ពោះទៅរកការអនុវត្តន៍ ប្រកបដោយជោគជ័យនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ដោយហ្វឹនហ្វឺន និង ផ្តល់អំណាចដល់អ្នកដឹកនាំក្រុមជំនុំ ដើម្បីលើកកម្ពស់សិទ្ធិកុមារ និង ជំនាញការចិញ្ចឹមបីបាច់ល្អ នៅក្នុងសហគមន៍របស់ពួកគាត់។

ចាប់តាំងពីឆ្នាំ២០១៦ គម្រោងវីអ៊ូធីស៊ី មានការផ្តោតថ្មីលើការផ្តល់អំណាចដល់សង្គមស៊ីវិល ចេតនាក្នុងការបង្កើតបណ្តាញ និង តស៊ូមតិធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន។ ការផ្តោតរបស់គម្រោង គឺពង្រីកការសហការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ប្រធានភូមិ កងកម្លាំងប៉ូលីស និង សាលារៀនរដ្ឋ។ អ្នកដឹកនាំក្រុមជំនុំ បានទទួលការបណ្តុះបណ្តាលពីគម្រោងវីអ៊ូធីស៊ី កំពុងដើរតួនាទីក្នុងការភ្ជាប់បណ្តាញ និង តស៊ូមតិ។

លទ្ធផលល្អ គឺត្រូវបានគេមើលឃើញរួចទៅហើយ ពីការធ្វើការដោយផ្ទាល់ ជាមួយគ្រូបង្រៀនសាលារដ្ឋ បន្ទាប់ពីបានធ្វើការបណ្តុះបណ្តាលជំនាញចិញ្ចឹមបីបាច់កូន ដល់គ្រូសាលារដ្ឋ អ្នកចូលរួម បង្ហាញការយល់ដឹងថ្មីនៃដំណាក់កាល អភិវឌ្ឍន៍របស់កុមារ។ ពួកគាត់ ក៏បានទទួលការយល់ដឹងថ្មី អំពីគុណតម្លៃរបស់កុមារ អំពីតួនាទីរបស់ឪពុកម្តាយ និង អ្នកមើលថែទាំ។ នេះ គឺជាការផ្លាស់ប្តូរផ្នត់គំនិតមួយដែលជាស្នូលសម្រាប់ផ្លាស់ប្តូរប្រពៃណី និង ទម្លាប់ចាស់ និង ជាការចាក់គ្រឹះសម្រាប់សុខុមាលភាពកុមារឲ្យកាន់តែប្រសើរឡើង នៅក្នុងប្រទេសកម្ពុជា។

ការធ្វើឲ្យជីវភាពរស់នៅប្រសើរឡើង សម្រាប់ប្រជាជន ដែលងាយរងគ្រោះក្នុងប្រទេសកម្ពុជា គឺមិនមែនគ្រាន់តែជាភារកិច្ចរបស់អាជ្ញាធរក្នុងការដោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែជាការខិតខំប្រឹងប្រែងរួមគ្នា និងការសហការរវាងសង្គមស៊ីវិលនិងអាជ្ញាធរ។ គម្រោងវីអាយឌីភីរបស់អង្គការអោយស៊ីស៊ី (អភិវឌ្ឍន៍សមាហរកម្មភូមិ) ក៏ដូចគ្នាទៅនឹងគម្រោងវីអ៊ូធីស៊ីកំពុងធ្វើការឆ្ពោះទៅរកការផ្តល់អំណាចដល់សហគមន៍មូលដ្ឋាន ប៉ុន្តែរយៈការសហការជាមួយអាជ្ញាធរមូលដ្ឋាន។ ក្នុងឆ្នាំ២០១៦ គម្រោងវីអាយឌីភីបានធ្វើការឆ្ពោះទៅរកការបំពាក់បំប៉ន និង ផ្តល់អំណាចដល់ក្រុមជំនុំគោលដៅមូលដ្ឋាន ដើម្បីសហការជាមួយអាជ្ញាធរដើម្បីជានាឲ្យបាននូវការអភិវឌ្ឍសហគមន៍សម្រាប់អ្នកភូមិទាំងអស់មិនត្រឹមតែសម្រាប់អ្នកភូមិជាគ្រីស្ទបរិស័ទនោះទេ។ ទំនាក់ទំនងទៅអាជ្ញាធរនេះ បើកឱកាសសម្រាប់ការតស៊ូមតិ ទាំងគម្រោងវីអាយឌីភី និង វីអ៊ូធីស៊ី។



## ការច្នៃបង្កើតថ្មី និង ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

គម្រោងអាយប៊ីស៊ីឌីអ៊ី របស់អង្គការអោយស៊ីស៊ី (អប់រំ និង អភិវឌ្ឍសហគមន៍ផ្អែកលើអត្តសញ្ញាណ) បច្ចុប្បន្ន កំពុងធ្វើការជាមួយសហគមន៍ជនជាតិដើមភាគតិច នៅក្នុងតំបន់ភាគឦសាននៅក្នុងខេត្តរតនគិរី និង មណ្ឌលគិរី ដោយប្រើវិធីសាស្ត្រច្នៃបង្កើតថ្មីដែលហៅថា "ក្រុមការងារសន្ទនា"។ គោលបំណងនៃការប្រើក្រុមការងារសន្ទនានេះ គឺធ្វើការដោយប្រុងប្រយ័ត្ន ក្នុងកិច្ចសន្ទនាជាមួយសហគមន៍គោលដៅ ដើម្បីកំណត់តម្រូវការរបស់ពួកគេ និង រួមគ្នាបង្កើតដំណោះស្រាយដែលអាចធ្វើទៅបាន។ ក្រុមការងារសន្ទនា របស់អាយប៊ីស៊ីឌីអ៊ី បានប្រើឧបករណ៍នានា មានប្រយោជន៍ សម្រាប់សហគមន៍ ដើម្បីប្រមើមើលអ្វីដែលពួកគេចង់ធ្វើឲ្យប្រសើរឡើង និង របៀបធ្វើឲ្យវាកើតឡើង។ ប្រជាជនកម្ពុជាជាមធ្យម និង ជាពិសេស ជនជាតិដើមភាគតិចមិនធ្លាប់សម្តែងមតិ និង បង្ហាញការយល់ឃើញរបស់ពួកគេទេ ហេតុនេះ ក្រុមការងារសន្ទនា លើកទឹកចិត្ត និង ផ្តល់អំណាចដល់ពួកគេឲ្យហ៊ានចែកចាញសម្លេង សហគមន៍រួមរបស់ពួកគាត់។ គម្រោងអាយប៊ីស៊ីឌីអ៊ីបានមើលឃើញលទ្ធផលយ៉ាងសំខាន់ពីវិធីសាស្ត្រនេះនៅឆ្នាំ២០១៦ ហើយឥឡូវនេះសហគមន៍ កាន់តែមានការលើកទឹកចិត្តបន្ថែមទៀត និងចូលរួមក្នុងការអភិវឌ្ឍន៍សហគមន៍របស់ពួកគេ បើប្រៀបធៀបទៅនឹងឆ្នាំមុន។

ឧទាហរណ៍អំពី របៀបសន្ទនាដែលជួយសម្រួលដល់សហគមន៍ចាត់វិធានការ ដោះស្រាយជាមួយនឹងបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេមកពីអ្នកភូមិជនជាតិដើមជាកន្លែងដែលសព្វថ្ងៃនេះ ស្ត្រីហ៊ាននិយាយអំពី ប្រធានបទសុខភាពសើបៗ។

ឥឡូវនេះ ស្ត្រីទាំងនេះមានចំណាប់អារម្មណ៍ ក្នុងការពិភាក្សាអំពីបញ្ហាសុខភាពរបស់ពួកគេដោយបើកចំហ ក្នុងគោលបំណងដើម្បីស្វែងរកវិធីដើម្បីការពារសុខភាពរបស់ពួកគេ និង ដើម្បីស្វែងរកការថែរក្សាសុខភាពឲ្យបានត្រឹមត្រូវ។

បើទោះបីជា នៅតែមានការងារជាច្រើនទៀតដើម្បីបញ្ចប់ មុនពេលដែលសហគមន៍គោលដៅជនជាតិដើមភាគតិច ឈានដល់ទស្សនៈរបស់ពួកគេយ៉ាងពេញលេញ សហគមន៍បានមើលឃើញសារៈប្រយោជន៍នៃការធ្វើការរួមគ្នាជាមួយនឹងក្រុមការងារសន្ទនារបស់គម្រោងអាយបីស៊ីឌីអី ព្រោះថាពួកគេជឿថាការងារអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាពត្រូវតែកើតឡើងជាមួយនឹងការចូលរួមរបស់ពួកគេ។



## ផែនការសម្រាប់ឆ្នាំ២០១៧

ចាប់ពីដើមឆ្នាំ២០១៧ គម្រោងឆ្លើយតបការជួញដូរមនុស្ស នឹងចាប់ផ្តើមដំណាក់កាលទី១ ដោយផ្អែកលើមេរៀនដែលបានរៀនក្នុងអំឡុងពេលដំណាក់កាលសាកល្បងក្នុងឆ្នាំ២០១៦ លើសពីនេះទៀត ការអន្តរាគមន៍បន្ថែមរបស់គម្រោងវីអ៊ូធីស៊ីទាក់ទងទៅនឹងការតស៊ូមតិសិទ្ធិកុមារនឹងត្រូវបានរៀបចំឡើង ដោយផ្អែកលើការសិក្សា ផែនការគ្រោងនឹងត្រូវធ្វើ ក្នុងឆ្នាំ២០១៧។

អង្គការអាយស៊ីស៊ី នៅតែមានការលើកទឹកចិត្តយ៉ាងខ្លាំង ដើម្បីចូលរួមនៅក្នុង ការធ្វើអន្តរាគមន៍ ផ្នែកការថែទាំជីវិតចុងក្រោយ និង ផ្នែកបរិស្ថាន។ ដំណើរការឆ្ពោះទៅរកកិច្ចអន្តរាគមន៍ថ្មីទាំងពីរ នឹងត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងឆ្នាំ២០១៧ ដើម្បីកំណត់ពីការចូលរួម ប្រកបដោយភាពច្នៃប្រឌិតថ្មីល្អបំផុតរបស់អង្គការអាយស៊ីស៊ី ក្នុងវិស័យទាំងពីរនេះ។ ដូចគ្នានេះផងដែរ អង្គការផ្តល់អាទិភាពលើ កម្មវិធីអាយស៊ីស៊ីប៊ីយ៉ននិងការបង្កើតយុទ្ធសាស្ត្រទីផ្សារនឹងត្រូវអភិវឌ្ឍ ក្នុងគោលបំណងឲ្យគេស្គាល់ និង ធ្វើឲ្យទាក់ទាញក្នុងចំណោមអង្គការសង្គមស៊ីវិលនៅកម្ពុជា។

ក្នុងឆ្នាំ២០១៧ អង្គការអាយស៊ីស៊ី នឹងសាកល្បងវិធីសាស្ត្រថ្មីមួយនៃបញ្ហាឆ្លងប្រព័ន្ធរបស់អង្គការអាយស៊ីស៊ី (ស៊ីស៊ីអាយ)។ គោលបំណង គឺដើម្បីបង្កើតគ្រោង និង ដំណើរការដែលនឹងអនុញ្ញាតឲ្យសកម្មភាពស៊ីស៊ីអាយ ជាចេតនា និង គោលដៅដើម្បីចូលរួមចំណែក ដោយជោគជ័យដល់ការងារអភិវឌ្ឍន៍របស់អង្គការអាយស៊ីស៊ី។

ផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់អង្គការអាយស៊ីស៊ី នឹងផុតកំណត់នៅចុងឆ្នាំ២០១៧ ហេតុនេះ ដំណើរការនៃការកែសម្រួល ផែនការយុទ្ធសាស្ត្របច្ចុប្បន្ន នឹងធ្វើឡើងពេញមួយឆ្នាំនេះ។ គោលបំណង គឺមិនមែនបង្កើតផែនការយុទ្ធសាស្ត្រអង្គការអាយស៊ីស៊ីថ្មីទាំងស្រុងពីឆ្នាំ២០១៨តទៅនោះទេ ប៉ុន្តែគឺដើម្បីកសាងលើភាពខ្លាំង និង ឱកាសរបស់អង្គការអាយស៊ីស៊ីក្នុងទិសដៅយុទ្ធសាស្ត្រ និង ការផ្តោត នៅពេលបច្ចុប្បន្ន។ ស្ថិតលើកម្រិតរបស់ស្ថាប័នអង្គការ អាយស៊ីស៊ី នៅតែបន្តពង្រឹង និង ពង្រីកការចូលរួមរបស់ខ្លួនជាមួយនឹងយុទ្ធសាស្ត្រ តស៊ូមតិ និង គុណភាពគ្រប់គ្រង។ ការណ៍នេះ នឹងធ្វើឲ្យ អង្គការអាយស៊ីស៊ី ស្ថិតនៅក្នុងតម្លៃជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលមានលទ្ធិភាពអាចឆ្លើយតបទៅនឹងតម្រូវការ និង សំណើរប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ទាំងក្នុងឆ្នាំ២០១៧ និងពេលអនាគត។

## ការដឹងគុណ

សូមថ្លែងអំណរគុណដល់បណ្តាក្រសួង និងអង្គការនានាដែលផ្តល់នូវការគាំទ្រ និងជំនួយសប្បុរស ដែលមានសារៈសំខាន់បំផុតសម្រាប់ការងាររបស់អាយស៊ីស៊ីក្នុងប្រទេសកម្ពុជា៖

ក្រសួងការបរទេស និងសហប្រតិបត្តិការបរទេស ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល និង អង្គការនានាដូចជា Interact; Cambodia Action; SIL International; Normisjon; Viator; Digni; FELM; Tearfund UK; TEAR Australia; Transform Aid Int.; LEAD Asia; ECHO Asia; EFC; CCC; Micah Network; NGO Education Partnership និង MRO.